អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត

សហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានធ្វើការកត់សម្គាល់សេចក្តីប្រកាសព័ត៌មានដែលមានចំណងជើងថា *"សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសំណុំរឿង ០០៣"* (សេចក្តីប្រកាសព័ត៌មាន) ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១។

ក្រៅពីដំណឹងមួយចំនួនផ្សេងទៀត សេចក្តីប្រកាសព័ត៌មាននេះ បានផ្តល់នូវព័ត៌មានស្តីពីឧក្រិដ្ឋកម្ម ដែលបើតាមគំនិតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តម្រូវឲ្យមានការស៊ើបសួរ ហើយដែលក្នុងនោះដែរ បានបង្ហាញព័ត៌មានពិស្តារទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងសំណុំរឿង ០០៣ ទីតាំងឧក្រិដ្ឋកម្ម និងផែនការឧក្រិដ្ឋកម្មនានា។ ជាងនេះទៅទៀត សេចក្តីប្រកាសព័ត៌មាន ក៏បានលើកឡើងពីព័ត៌មានស្តីពីសកម្មភាពនានា ដែលបម្រុងនឹងធ្វើនាពេលអនាគត ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងដំណើរការស៊ើបសួរ។

សហព្រះរាជអាជ្ញាអន្តរជាតិខ្វះខាតនូវមូលដ្ឋានច្បាប់ ក្នុងការប្រកាសព័ត៌មានទាំងឡាយខាងលើជាសាធារណៈ ហើយគាត់ក៏បានរំលោភលើវិធានស្តីពីភាពសម្ងាត់ផងដែរ។ សម្រាប់ហេតុផលទាំងនេះ សហចៅក្រមស៊ើបអង្កេតបានចេញនូវដីកាដែលមានសំអាងហេតុមួយច្បាប់ ដែលនៅក្នុងនោះ សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានដាក់កំហិតឲ្យធ្វើការដកយកផ្នែកខ្លះចេញពីសេចក្តីប្រកាសព័ត៌មានខាងលើ មិនឲ្យហួសពីរយៈពេលបីថ្ងៃការងារ។

ដីកានេះអាចនឹងទាញយកមកអានបានទាំងស្រុងពីគេហទំព័ររបស់ អ.វ.ត.កៈ
https://www.eccc.gov.kh/sites/default/files/documents/courtdoc/D14_EN.PDF



Original EN: 01699228-01699229